# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១៦

## ជប៉ុនផ្តល់ថវិកាសរុបចំនួន ៣៣០,២៦៩ ដុល្លារអាមេរិក សម្រាប់ការអនុវត្តគម្រោងចំនួនបួន

ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណេ) រដ្ឋាភិបាលជប៉ុន បានយល់ព្រមផ្តល់ថវិកាសរុបចំនួន **៣៣០,២៦៩ ដុល្លារអាមេរិក** ដល់អង្គភាពទទួលជំនួយចំនួនបួន។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ **ឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយទាំងបួនសម្រាប់គម្រោងដូចតទៅ៖

**១. គម្រោងសាងសង់អគារផ្នែកសម្ភព និងជម្ងឺកុមារ នៅមន្ទីរពេទ្យបង្អែកភ្នំស្រុក ខេត្តបន្ទាយមានជ័យ (ថវិកាចំនួន៨២,១៤៥ ដុល្លារអាមេរិក)**

អង្គភាពទទួលជំនួយ៖ មន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ

គម្រោងនេះ នឹងសាងសង់អគារផ្នែកសម្ភព និងជម្ងឺកុមារមួយខ្នង នៅមន្ទីរពេទ្យបង្អែកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។ មួយនឹងគម្រោងនេះ ស្ត្រីមានផ្ទៃពោះប្រមាណជា ៣៦០នាក់ និងកុមារប្រមាណជា ១,៩០០នាក់ នឹងអាចទទួលបានសេវាសុខភាពកាន់តែល្អប្រសើរជាងមុន ។

**២. គម្រោងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រវាលស្តៅ ខេត្តកំពង់ចាម (ថវិកាចំនួន ៨២,៥២៤ ដុល្លារអាមេរិក)**

អង្គភាពទទួលជំនួយ៖ មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ចាម

គម្រោងនេះ នឹងស្តារឡើងវិញនូវទំនប់មួយខ្សែប្រវែង ៤៨០ម៉ែត្រ ផ្លូវភ្ជាប់ទំនប់មួយខ្សែប្រវែង ១,៤៥០ម៉ែត្រ និងសំណង់ទ្វារទឹកចំនួន២កន្លែង ព្រមទាំងការសាងសង់សំណង់លូទឹកចំនួន៤កន្លែង ដើម្បីពង្រីកផ្ទៃដីដាំដុះ ក្នុងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ គម្រោងនេះត្រូវបានរំពឹងថា ប្រជាកសិករប្រមាណជា ៣,៥០០នាក់ នឹងទទួលបានទឹកស្រោចស្រពលើដីស្រែរបស់ពួកគេកាន់តែច្រើន បន្ទាប់ពីបញ្ចប់គម្រោងនេះ។

**៣. គម្រោងសាងសង់អគារមជ្ឈមណ្ឌលសហគមន៍កសិកម្ម ខេត្តស្ទឹងត្រែង (ថវិកាចំនួន ៨៣,០០០ ដុល្លារអាមេរិក)**

អង្គភាពទទួលជំនួយ៖ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

គម្រោងនេះ នឹងសាងសង់អគារមជ្ឈមណ្ឌលសហគមន៍កសិកម្មចំនួន៣កន្លែង សម្រាប់សហគមន៍កសិកម្មចំនួន៣ និងផ្តល់ជូននូវម៉ាស៊ីនកសិកម្មរួមមាន៖ គោយន្តកន្ត្រៃ២គ្រឿង ម៉ាស៊ីនបោកស្រូវ២គ្រឿង ម៉ាស៊ីនបោកសណ្តែក១គ្រឿង ម៉ាស៊ីនកិនដំឡូងមី២គ្រឿង និងឡសម្ងួតស្រូវ១កន្លែង។ គម្រោងនេះត្រូវបានរំពឹងថា ប្រជាកសិករប្រមាណជា ៨០០នាក់ នឹងទទួលបាននូវអត្ថប្រយោជន៍ពីការប្រកបអាជីវកម្មរបស់សហគមន៍កសិកម្មទាំងបីនេះ។

## ៤. គម្រោងកែលម្អផ្លូវ ក្នុងភូមិប៉ាងរលឹម សង្កាត់អូរតាវ៉ៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន (ថវិកាចំនួន ៨២,៦០០ដុល្លារអាមេរិក)

អង្គភាពទទួលជំនួយ៖ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តប៉ៃលិន

គម្រោងនេះ នឹងធ្វើការសាងសង់លូប្រអប់ជ្រុងមុខបីចំនួន២កន្លែង ដើម្បីកែលម្អផ្លូវក្នុងក្រុងប៉ៃលិន ខេត្តប៉ៃលិន។ ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ប្រមាណជា ៤,៣០០នាក់ នឹងទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ។ គម្រោងនេះ ត្រូវបានរំពឹងថា ការកែលម្អផ្លូវនេះ នឹងផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋ និងសិស្សានុសិស្ស ក្នុងការធ្វើដំណើរឆ្លងកាត់ទៅកាន់សាលារៀន មន្ទីរពេទ្យ និងផ្សារនានា ព្រមទាំងជួយលើកស្ទួយដល់ការដឹកជញ្ជូនកសិផលនានាចូលទៅកាន់ទីផ្សារផងដែរ។

*ជំនួយឥតសំណងគូសាណូណិរបស់ជប៉ុន* បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសល ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥៥លានដុល្លារអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិចំនួន៥៦២ គម្រោងនៅទូទាំងប្រទេសកម្ពុជា។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*